# ការស្ទង់មតិ
# មាតាបិតា និង អាណាព្យាបាល
# ឆ្នាំ២០១៧




## ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

បំពេញការស្ទង់មតិ មាតាបិតា និង អាណាព្យាបាល ទូទាំងក្រសួង

**www.philasd.org/parentsurvey/index.php?lang=km**

កូនរបស់លោកអ្នក
យោបល់របស់លោកអ្នក
អាចកែឆ្នៃសាលារបស់លោកអ្នក!



## តើចម្លើយត្រូវបានគេប្រើយ៉ាងដូចម្តេច?

មតិយោបល់ដែលបានមកពីការស្ទង់មតិ នឹងត្រូវគេប្រើដើម្បី៖

— ឲ្យដឹងពី គំនិត ទស្សនៈ និងការយល់ឃើញ របស់មាតាបិតា និងអាណាព្យាបាល ចំពោះសាលា

— រកមើលភាពខ្លាំងពូកែរបស់សាលា និងឱកាសដើម្បីកែលម្អ

— តម្រង់ទិសក្នុងការស្រាវជ្រាវនាពេលអនាគត

— ផ្តល់ព័ត៌មានអំពីវិធីវាយតម្លៃសាលា

## តើខ្ញុំអាចបំពេញការស្ទង់មតិនៅទីណា?

លោកអ្នកអាចបំពេញការស្ទង់មតិតាមកុំព្យូទ័រ ឬតាមទូរស័ព្ទទំនើប។ បើសិនជាលោកអ្នកគ្មានឧបករណ៍ទាំងពីរនេះទេ លោកអ្នកអាចបំពេញការស្ទង់មតិនៅតាមកន្លែងដូចតទៅនេះ៖

— សាលារបស់កូនលោកអ្នក

— មណ្ឌលផ្តល់ជំនួយដល់ មាតាបិតា និង ក្រុមគ្រួសារ របស់ក្រសួងអប់រំ

— បណ្ណាល័យរដ្ឋក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា

— កន្លែង Keyspot ក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា

— អង្គការក្នុងសហគមន៍ ដែលចូលរួម (សូមមើលវិបសៃសម្រាប់ ការស្រាវជ្រាវ និង ការវាយតម្លៃ)

## ព័ត៌មានសំខាន់ៗនៃការស្ទង់មតិ

១. ការស្ទង់មតិនេះ ត្រូវចំណាយពេលបំពេញប្រហែលជា ៥ ទៅ ១០ នាទី។

២. ការស្ទង់មតិ មាតាបិតា និងអាណាព្យាបាល ក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា នឹងមាននៅក្នុងទំព័រវិបសៃសម្រាប់មាតាបិតា និងនៅក្នុងវិបសៃ **philasd.org/parentsurvey** ពីម៉ោង ៩:០០ ព្រឹក នៃថ្ងៃទី៣ ខែមេសា ឆ្នាំ ២០១៧ រហូតដល់ម៉ោង ៥:០០ ល្ងាច នៃថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។

៣. លោកអ្នកត្រូវការអត្តលេខសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា របស់កូនលោកអ្នក ដើម្បីបំពេញការស្ទង់មតិនេះ។ បើសិនជាកូនរបស់លោកអ្នកទៅរៀននៅសាលារបស់ក្រសួងអប់រំ លោកអ្នកអាចឃើញលេខនេះនៅក្នុងរបាយការណ៍ពិន្ទុរបស់កូនលោកអ្នក។ បើសិនជាកូនរបស់លោកអ្នកទៅរៀននៅសាលាឆាទ័រ សូមទាក់ទងសាលារបស់កូនលោកអ្នក ដើម្បីសុំអត្តលេខរបស់សិស្ស។ បើសិនជាលោកអ្នករកលេខនេះមិនឃើញ សូមទាក់ទងសាលារបស់កូនលោកអ្នក ឬទូរស័ព្ទទៅលេខសម្រាប់ការស្ទង់មតិ។

៤. ការស្ទង់មតិនេះនឹងមានជា៨ភាសា។

៥. សុំឲ្យលោកអ្នកបំពេញការស្ទង់មតិផ្សេងៗគ្នា សម្រាប់កូនលោកអ្នកម្នាក់ៗ។

៦. ការស្ទង់មតិត្រូវគេរក្សាទុកជាសម្ងាត់។ ចម្លើយរបស់លោកអ្នកនឹងត្រូវគេបញ្ចូលឡុកឡំជាមួយនឹងចម្លើយដែលបានមកពីមាតាបិតា និងអាណាព្យាបាលដទៃទៀត។

### មានសំណួរ?

ការស្ទង់មតិ ចប់នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ បើសិនជាលោកអ្នកមានបញ្ហាក្នុងការចុចចូល ឬមានសំណួរអ្វីដែលទាក់ទងនឹងការស្ទង់មតិនេះ សូមទាក់ទងក្រុមរៀបចំការស្ទង់មតិលេខ ២១៥-៤០០-៨៤៨៤ ឬ www.philasd.org/language/khmer